00548010

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification):
31 / 08 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

D370/2/11

តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៦៣)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Catherine MARCHI-UHEL
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១០

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception):
31 / 08 / 2010
ម៉ោង (Time/Heure): 9:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

## សាធារណៈ

## សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំដាក់បញ្ចូលឯកសារទាំងឡាយពាក់ព័ន្ធនឹងសកម្មភាពជាក់ស្តែងរបស់លោក ខៀវ សំផន"

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនត្រូវចោទ**
ខៀវ សំផន

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ចាន់ ឌី
Mahdev MOHAN
Lima NGUYEN
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Elizabeth-Joelle RABESANDRATANA

**សហមេធាវីការពារក្តីជនត្រូវចោទ**
ស ស្វាន
Jacques VERGÈS
Philippe Greciano

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C. * C.E.T.C.

00548011



Annie DELAHAIE
Philippe CANONNE
Martine JACQUIN
Fabienne TRUSSES-NAPROUS
Françoise GAUTRY
Isabelle DURAND
Christine MARTINEAU
Laure DESFORGES
Ferdinand DJAMMEN-NZEPA
ឡោ ជុនធី
ស៊ីន សុវ៉ន
សំ សុគង់
ហុង គីមសួន
គង់ ពិសី
គង់ ហេង
Silke STUDZINSKY
Olivier BAHOUGNE
Marie GUIRAUD
Partirck BAUDOUIN
ជេត វណ្ណលី
ពេជ អង្គ
Julien RIVET
Pascal AUBOIN
យុង ផានិត

00548012



**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា("**អ.វ.ត.ក**")បានឃើញការដាក់ឯកសារ "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំដាក់បញ្ចូលឯកសារទាំងឡាយពាក់ព័ន្ធ នឹងសកម្មភាពជាក់ស្តែងរបស់លោក ខៀវ សំផន"[១] ("បណ្តឹងឧទ្ធរណ៍") នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១០ ដែលបានដាក់ដោយ ខៀវ សំផន ("ម្ចាស់បណ្តឹងឧទ្ធរណ៍")។

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១០ ម្ចាស់បណ្តឹងឧទ្ធរណ៍បានដាក់ "សំណើសុំដាក់បញ្ចូលឯកសារដែលពាក់ព័ន្ធនឹងសកម្មភាពដ៏ពិតប្រាកដរបស់លោក ខៀវ សំផន ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ"[២] ("សំណើសុំ")។ ម្ចាស់បណ្តឹងឧទ្ធរណ៍ បានស្នើសុំសហចៅក្រមស៊ើបអង្កេតឱ្យដាក់ទៅក្នុងសំណុំរឿងនូវ"ឯកសារចំនួន៦០០ ដែលត្រូវបានប្រើប្រាស់ជាឯកសារយោង នៅក្នុងរបាយការណ៍វិភាគរបស់ លោក [Craig C.] Etcheson ដែលនៅមិនទាន់ត្រូវបានបញ្ចូលទៅក្នុងសំណុំរឿងនៅឡើយ" និងសុំឱ្យធ្វើការបកប្រែឯកសារទាំងនោះជាភាសាការងារជាផ្លូវការរបស់អង្គជំនុំជម្រះវិសាមញ្ញ ចំនួនពីរភាសាផ្សេងទៀត[៣]។

២. នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញ "ដីកាសម្រេចស្តីពីសំណើសុំដាក់បញ្ចូលឯកសារពាក់ព័ន្ធដល់សកម្មភាពជាក់ស្តែងរបស់លោក ខៀវ សំផន"[៤] ("ដីកា") ដោយបានបដិសេធលើសំណើសុំ។ ដីកាត្រូវបានជូនដំណឹងជាបីភាសាការងារជាផ្លូវការរបស់អង្គជំនុំជម្រះវិសាមញ្ញ កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១០។

---

[១] បណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹង "ដីកាសម្រេចលើសំណើសុំដាក់បញ្ចូលឯកសារទាំងឡាយពាក់ព័ន្ធទៅនឹងសកម្មភាពជាក់ស្តែងរបស់លោក ខៀវ សំផន" ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១០ ឯកសារ D370/2/1 ("បណ្តឹងឧទ្ធរណ៍")។

[២] សំណើសុំដាក់បញ្ចូលឯកសារដែលពាក់ព័ន្ធនឹងសកម្មភាពដ៏ពិតប្រាកដរបស់លោក ខៀវ សំផន ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០១០ ឯកសារ D370 ("សំណើ")។ ឯកសារជាភាសាបារាំង និងភាសាខ្មែរត្រូវបានដាក់នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១០ ហើយឯកសារជាភាសាអង់គ្លេសត្រូវបានដាក់នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១០។

[៣] សំណើ កថាខណ្ឌ ៧។

[៤] ដីកាសម្រេចស្តីពី "សំណើសុំដាក់បញ្ចូលឯកសារពាក់ព័ន្ធដល់សកម្មភាពជាក់ស្តែងរបស់ ខៀវ សំផន" ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១០ ឯកសារ D370/1 ("ដីកាសម្រេច")។

៣. នៅថ្ងៃទី២៤ខែមីនាឆ្នាំ២០១០ ម្ចាស់បណ្ដឹងឧទ្ធរណ៍បានដាក់សេចក្ដីជូនដំណឹងស្ដីពីបណ្ដឹងឧទ្ធរណ៍[៥] ប្រឆាំងនឹងដីកា ហើយនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១០ បានដាក់សេចក្ដីសន្និដ្ឋានរបស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍[៦]។

៤. ពុំមានចម្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍ណាមួយត្រូវបានដាក់ អនុលោមតាមមាត្រា៨.៣នៃសេចក្ដីណែនាំអនុវត្តស្ដីពី "ការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក" នោះឡើយ[៧]។

៥. នៅថ្ងៃទី២០ខែឧសភាឆ្នាំ២០១០ភាគីនានាត្រូវបានជូនដំណឹងអំពីដីកាកំណត់កាលបរិច្ឆេទសវនាការដេញដោលផ្ទាល់មាត់លើបណ្ដឹងឧទ្ធរណ៍នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១០ នៅវេលាម៉ោង ២:០០រសៀល[៨]។ នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១០ ម្ចាស់បណ្ដឹង ឧទ្ធរណ៍បានដាក់ "សំណើសុំជាបន្ទាន់របស់ក្រុមមេធាវីការពារក្ដីទាក់ទងនឹងសវនាការ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១០" ("សំណើសុំបន្ទាន់") ដោយបានលើកឡើងនូវសំណើសុំ ចំនួនបីពាក់ព័ន្ធទៅនឹងសវនាការដេញដោល[៩]។ នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១០ ភាគីនានាត្រូវបានជូនដំណឹងអំពីដីកាសម្រេចលុបចោលសវនាការ និង ធ្វើការសម្រេចលើបណ្ដឹងឧទ្ធរណ៍ ដោយផ្អែកតែលើសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ

---

[៥] សៀវភៅចុះបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១០ ឯកសារ D370/2។ យោងតាមសៀវភៅចុះបណ្ដឹងឧទ្ធរណ៍នេះ ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត "បានទទួលការជូនដំណឹងស្ដីពីបណ្ដឹងឧទ្ធរណ៍" នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ វេលាម៉ោង ២ល្ងាច។ សៀវភៅចុះបណ្ដឹងឧទ្ធរណ៍ជាភាសាខ្មែរ និងភាសាបារាំងត្រូវបានដាក់នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១០ ហើយភាសាអង់គ្លេស ត្រូវបានដាក់នៅថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១០។

[៦] បណ្ដឹងឧទ្ធរណ៍ជាភាសាបារាំងត្រូវបានដាក់នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១០ ហើយជាភាសាខ្មែរនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១០។ បណ្ដឹងឧទ្ធរណ៍ជាភាសាអង់គ្លេសត្រូវបានដាក់ឡើងវិញនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១០ ដោយភ្ជាប់ជាមួយនូវការកែតម្រូវពីរ ដូចមានរៀបរាប់ក្នុងសំណើសុំធ្វើការកែប្រែ ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D370/2/1/Corr.1។

[៧] អ.វ.ត.ក/០១/២០០៧/វិសោធនកម្មលើកទី ៤ (ត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៩)។

[៨] ដីកាកំណត់កាលបរិច្ឆេទសវនាការ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១០ ឯកសារ D270/2/2។ ដីកាកំណត់កាលបរិច្ឆេទសវនាការនេះ ត្រូវបានជូនដំណឹងជាភាសាអង់គ្លេស និងភាសាខ្មែរនៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១០ និងជាភាសាបារាំងនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០។

[៩] ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១០, ឯកសារ D370/2/8 ("សំណើសុំបន្ទាន់")។ សំណើសុំបន្ទាន់ជាភាសាបារាំង និងភាសាខ្មែរត្រូវបានជូនដំណឹងនៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១០។ សំណើសុំបន្ទាន់ជាភាសាអង់គ្លេសត្រូវបានជូនដំណឹង នៅថ្ងៃ ទី១៤ ខែមិថុនា ឆ្នាំ២០១០។

ប៉ុណ្ណោះ[១០]។ នៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានជូនដំណឹងអំពី "សេចក្តីសម្រេច លើសំណើសុំ" ដោយបានបដិសេធសំណើសុំនោះ ដោយហេតុថា សវនាការដេញដោល ត្រូវបាន លុបចោល សំណើសុំនេះមិនមានប្រយោជន៍ទេ[១១]។

៦. នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានដាក់ចេញនូវការសម្រេចលើបណ្តឹងឧទ្ធរណ៍ ដោយបង្ហាញថា "សាលដីកាដែលមានសំអាងហេតុលើបណ្តឹងឧទ្ធរណ៍នេះ នឹងប្រកាសចេញនៅ ក្នុងពេលសមស្រប"[១២]។ ការសម្រេចសេចក្តីនោះត្រូវ បានសម្រេចថា:

> "១. មិនទទួលយកសំណើសុំនៅក្នុងបណ្តឹងឧទ្ធរណ៍ ពោលគឺ សំណើសុំឱ្យ"អនុញ្ញាត ដល់មេធាវីការពារក្តី ក្នុងការស្វែងរកភស្តុតាងដោយខ្លួនឯង ដើម្បីធានាដល់កិច្ចស្វែងរក ការពិត" សំណើសុំឱ្យ"បង្គាប់ទៅការិយាល័យព្រះរាជអាជ្ញា ឱ្យជូនដំណឹងទៅភាគីអំពី ឯកសារភស្តុតាងទាំងអស់ដែលខ្លួនមាន និងធានានូវការអនុវត្តសិទ្ធិរបស់មេធាវីការពារឱ្យ មានប្រសិទ្ធភាព" និងសំណើមួយទៀតសុំឱ្យ"ជាជម្រើស បង្គាប់ទៅសហចៅក្រមស៊ើប អង្កេតឱ្យដាក់បញ្ចូលទៅក្នុងសំណុំ រឿងស៊ើបសួរនូវឯកសារភស្តុតាងទាំងឡាយ ដែលស្នើ សុំដោយមេធាវីការពារក្តី"។
>
> ២. ទទួលយកសំណើនៅក្នុងបណ្តឹងឧទ្ធរណ៍ សុំឱ្យ "លុបចោលដីកាសម្រេច"។

---

[១០] ដីកាសម្រេចលុបចោលសវនាការ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១០ ឯកសារ D370/2/7។ ដីកាសម្រេចលុប ចោល សវនាការនេះ ត្រូវបានជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១០ និងជាភាសាបារាំងនិង ភាសាខ្មែរនៅ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១០។

[១១] សេចក្តីសម្រេចលើសំណើសុំ ឯកសារ D370/2/9 ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១០។ សេចក្តីសម្រេចជាភាសា អង់គ្លេស បារាំង និងខ្មែរត្រូវបានជូនដំណឹងនៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១០។

[១២] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំដាក់បញ្ចូលឯកសារទាំងឡាយពាក់ព័ន្ធនឹងសកម្មភាពជាក់ ស្តែងរបស់លោក ខៀវ សំផន ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D370/2/10។ សម្រេចសេចក្តីជាភាសាអង់គ្លេស និង ភាសាខ្មែរត្រូវបានជូនដំណឹងនៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១០ ហើយសម្រេចសេចក្តីជាភាសាបារាំងត្រូវបានជូនដំណឹងនៅ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១០។

00548015



៣. សហចៅក្រមស៊ើបអង្កេតមានកំហុសអង្គច្បាប់ នៅពេលខ្លួនមិនបានសន្និដ្ឋាន ថា ឯកសារដែលបណ្ឌិត Craig C. Etcheson បានយោងនៅក្នុងកថាខណ្ឌទី ៣១ និង កថាខណ្ឌទី ១៤៦ និងនៅក្នុងលេខយោង ជើងទំព័រទី ៣៤១ នៅក្នុងរបាយការណ៍វិភាគ ("របាយការណ៍ និងអនុស្សរណៈរាប់រយច្បាប់" និង"ឧទាហរណ៍ជាង ៦០០ នៅក្នុងលិខិត ឆ្លើយឆ្លងប្រភេទនេះ") គឺជាឯកសារដែលអាចជួយស្វែងរកការពិត *តាមការវិភាគបឋម*។

៤. បដិសេធបណ្តឹងឧទ្ធរណ៍ទុកជាឥតបានការ ដោយហេតុថា សំណើសុំ មិនបានកំណត់ កិច្ចស៊ើបសួរឲ្យបានជាក់លាក់គ្រប់គ្រាន់"។

## សំអាងហេតុនៃសេចក្តីសម្រេច

### II. ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ត្រូវបានពិចារណា

៧. សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់តាមពេលកំណត់ ដូចមានចែងនៅក្នុងវិធាន ៧៥(១)នៃវិធានផ្ទៃក្នុង។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ឯកសារបណ្តឹងឧទ្ធរណ៍ជាភាសា បារាំង ត្រូវបានដាក់តាមពេលវេលាកំណត់ដូចមានចែងនៅក្នុងវិធាន ៧៥(៣) នៃវិធានផ្ទៃក្នុង។ ក៏ ប៉ុន្តែ ផ្ទុយទៅនឹងមាត្រា ៧ នៃសេចក្តីណែនាំអនុវត្តស្តីពី "ការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក" ឯកសារបណ្តឹងឧទ្ធរណ៍ជាភាសាខ្មែរ ត្រូវបានដាក់ហួសរយៈពេលកំណត់នេះ។ អង្គបុរេជំនុំជម្រះ បានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ស្របតាមវិធាន៣៩(៤)(ខ)នៃវិធានផ្ទៃក្នុង ទទួលស្គាល់សុពលភាព នៃការដាក់បណ្តឹងឧទ្ធរណ៍ ទោះបីឯកសារបណ្តឹងឧទ្ធរណ៍ជាភាសាខ្មែរត្រូវបានដាក់ក្រោយពេល កំណត់ ដូចមានចែងនៅក្នុងវិធាន ៧៥(៣) នៃវិធានផ្ទៃក្នុងក៏ដោយ។ ពុំមានភាគីណាមួយត្រូវទទួល ទណ្ឌកម្ម ដោយសារតែការលំបាកតាមផ្លូវច្បាប់ក្នុងការទទួលបាននូវការបកប្រែឯកសារនោះទេ។

៨. ម្ចាស់បណ្តឹងឧទ្ធរណ៍ធ្វើបណ្តឹងឧទ្ធរណ៍ស្របតាមវិធាន ៧៤(៣)(ខ)នៃវិធានផ្ទៃក្នុង និងម្យ៉ាងទៀត ស្របតាមវិធាន២១(១) នៃវិធានផ្ទៃក្នុង[១៣]។

---

[១៣] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១, ២៤-៣៨។



E.C.C.C * C.E.T.C * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

00548016



៩. អង្គបុរេជំនុំជម្រះរំលឹកឡើងវិញថា វិធាន៧៤(៣)(ខ)នៃវិធានផ្ទៃក្នុងកំណត់លក្ខខណ្ឌថា បណ្ដឹងឧទ្ធរណ៍ត្រូវបំពេញនូវលក្ខខណ្ឌត្រួតគ្នាចំនួនបី ដើម្បីឲ្យមានការយល់ឃើញថា អាចទទួលយកបាន: ១)ម្ចាស់បណ្ដឹងឧទ្ធរណ៍ត្រូវតែបានដាក់សំណើសុំបំពេញកិច្ច ស៊ើបសួរជូនទៅសហចៅក្រមស៊ើបអង្កេត, ២) សំណើសុំនេះត្រូវទទួលបានការអនុញ្ញាតស្របតាមវិធានផ្ទៃក្នុង, និង ៣) សំណើសុំនេះត្រូវតែបានទទួលនូវការបដិសេធ ពីសហចៅក្រមស៊ើបអង្កេត។

១០. មកទល់នឹងពេលនេះ បណ្ដឹងឧទ្ធរណ៍អាចទទួលយកបាន ពីព្រោះ បណ្ដឹងឧទ្ធរណ៍ត្រូវបានផ្អែកលើការបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរសុំឲ្យដាក់បញ្ចូលនូវឯកសារនានា ទៅក្នុងសំណុំរឿងស្របតាមវិធាន៥៥(១០)នៃវិធានផ្ទៃក្នុង។ ម្ចាស់បណ្ដឹងឧទ្ធរណ៍បានស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតធ្វើការស្រាវជ្រាវ កំណត់អត្តសញ្ញាណ ឬវិភាគលើឯកសារទាំងឡាយ ដែលមិនមាននៅក្នុងឃ្លាំងផ្ទុកឯកសាររួម ឬដែលរក្សាទុកនៅDC-Cam ដែលមិនទាន់មាននៅក្នុងសំណុំរឿងនៅឡើយ និងសុំឲ្យដាក់ឯកសារទាំងនោះដែលសហចៅក្រមស៊ើបអង្កេតពិចារណាឃើញថា នឹងនាំទៅបង្ហាញនូវការពិត ទៅក្នុងសំណុំរឿង។ អង្គបុរេជំនុំជម្រះយល់ឃើញថា សំណើសុំនេះអាចចាត់ទុកជាសំណើសុំបំពេញកិច្ចស៊ើបសួរ នៅក្នុងអត្ថន័យនៃវិធាន៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង[១៤]។

១១. អង្គបុរេជំនុំជម្រះយល់ឃើញថា យោងតាមវិធាន៥៥(១០) ឬ៥៨(៦)នៃវិធានផ្ទៃក្នុង ពុំមានសំណើសុំសហចៅក្រមស៊ើបអង្កេតឲ្យដាក់ឯកសារមួយចំនួនឬឯកសារទាំងអស់ នៅក្នុងឧបសម្ព័ន្ធ ក នៃបណ្ដឹងឧទ្ធរណ៍ "ស្ដីពីសំណុំរឿងស៊ើបសួរ" ឬ បង្គាប់ទៅការិយាល័យសហព្រះរាជអាជ្ញាឲ្យបង្ហាញឯកសារភស្ដុតាងទាំងអស់ដែលខ្លួនមាន"នោះទេ[១៥]។ ទាំងអស់នេះជាសំណើសុំថ្មីៗដែលបានរៀបចំនៅក្នុងសំណូមពរនៅក្នុងបណ្ដឹងឧទ្ធរណ៍ ដែលអង្គបុរេជំនុំជម្រះគ្មានយុត្តាធិការពាក់ព័ន្ធនឹងសំណូមពរនេះទេ។ សំណើសុំទាំងនេះមិនអាចទទួលយកបានទេ យោងតាមវិធាន ៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង។

---

[១៤] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្ដីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគី ទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩ ឯកសារ A190/I/20កថាខណ្ឌ ២១-២៨។

[១៥] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៨៥។ *សូមមើលផងដែរ* បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៧១-៧៥។ *សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំដាក់បញ្ចូលឯកសារទាំងឡាយ ពាក់ព័ន្ធនឹងសកម្មភាពជាក់ស្ដែងរបស់លោក ខៀវ សំផន*

១២. វិធាន២១(១) នៃវិធានផ្ទៃក្នុងមិនអាចឲ្យអង្គបុរេជំនុំជម្រះយកមកអនុវត្តបាន ដើម្បីអនុញ្ញាតឲ្យម្ចាស់បណ្តឹងឧទ្ធរណ៍គេចវេះចេញពីនីតិវិធីទាំងឡាយដែលបានបង្កើតឡើង ដោយវិធាន៥៥(១០) និង ៥៨(៦) នៃវិធានផ្ទៃក្នុងនោះឡើយ។ ម្ចាស់បណ្តឹងឧទ្ធរណ៍ ទទួលរងនូវការទទួលខុសត្រូវតែមួយគត់ចំពោះផលវិបាកណាមួយ ដែលអាចកើតមាន ដោយសារការខកខានមិនអនុវត្តតាមនីតិវិធីទាំងអស់នេះ។ ហេតុដូច្នេះ សេចក្តីសន្និដ្ឋាន អំពីវិធាន២១(១)នៃវិធានផ្ទៃក្នុង របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ត្រូវបានបដិសេធចោល[១៦]។

## III. មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ត្រូវបានពិចារណា

### បទដ្ឋាននៃការពិនិត្យឡើងវិញនូវបណ្តឹងឧទ្ធរណ៍

១៣. អង្គបុរេជំនុំជម្រះរំលឹកថា ដីការបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំបំពេញកិច្ចស៊ើបសួរគឺជាដីកាធ្វើឡើងតាមឆន្ទានុសិទ្ធិ។ ដើម្បីឲ្យអង្គបុរេជំនុំជម្រះធ្វើការបដិសេធការអនុវត្តឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបង្ហាញថា ដីកាដែលត្រូវបានជំទាស់: (១) ផ្អែកលើការបកស្រាយមិនត្រឹមត្រូវនៃច្បាប់ជាធរមាន (២) ផ្អែកលើការមិនត្រឹមត្រូវទាល់តែសោះ ទៅលើអង្គហេតុ និង/ឬ (៣) អយុត្តិធម៌ ឬមិនសមហេតុផលដែលនាំឲ្យមានការរំលោភបំពានឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត[១៧]។ អង្គបុរេជំនុំជម្រះបានរំលឹកថែមទៀតថា មិនមែនរាល់កំហុសទាំងអស់នឹងនាំឲ្យអង្គបុរេជំនុំជម្រះសម្រេចទុកជាមោឃៈនូវសេចក្តីសម្រេចឬដីការបស់សហចៅក្រមស៊ើបអង្កេតនោះទេ។ អនុលោមតាមវិធាន៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះនឹងទុកជាមោឃៈនូវសេចក្តីសម្រេច ឬដីកាណាមួយ នៅពេលដែលកំហុសដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត គឺជាការកំណត់សម្រេចអំពីការអនុវត្តឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតដែលនាំឲ្យចេញនូវសេចក្តីសម្រេច ឬដីកា ដែលត្រូវបានប្តឹងឧទ្ធរណ៍។

### សំណើសុំរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍

---

[១៦] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៣-៣៨។

[១៧] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃ ទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ ២៥-២៧។

១៤. នៅក្នុងកថាខណ្ឌទី ១ នៃសំណើសុំរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ ក្រោមចំណងជើង "សេចក្ដីផ្ដើម" ម្ចាស់បណ្ដឹងឧទ្ធរណ៍ស្នើសហចៅក្រមស៊ើបអង្កេតឱ្យដាក់បញ្ចូលទៅក្នុងសំណុំរឿង "នូវបណ្ដាឯកសារទាក់ទិននឹងសកម្មភាពរបស់លោក ខៀវ សំផន ក្នុងនាមលោកជា 'អ្នកទទួលបន្ទុករណសិរ្ស រាជរដ្ឋាភិបាល ពាណិជ្ជកម្ម ខាងបញ្ជី និងតម្លៃ'"[១៨]។ ម្ចាស់បណ្ដឹងឧទ្ធរណ៍បន្តលើកឡើងនៅក្នុងកថាខណ្ឌទី ២ នៃសំណើសុំ របស់ខ្លួនទៀតថា "បញ្ជីផ្ទុកឯកសាររួមមានកម្រងឯកសារមួយ... ដែល ... មានសារៈ-សំខាន់ខ្លាំងណាស់ ព្រោះវាឆ្លុះបញ្ចាំងពីសកម្មភាពរបស់លោក ខៀវ សំផន ក្នុងនាមលោកជា"សមាជិកទទួលបន្ទុកខាងបញ្ជី"ក្នុងសម័យកាលនៃរបបកម្ពុជាប្រជាធិប-តេយ្យ" [១៩]។

១៥. នៅចុងបញ្ចប់នៃសំណើសុំ ម្ចាស់បណ្ដឹងឧទ្ធរណ៍បង្ហាញថា វិសាលភាពនៃសំណើសុំ របស់ខ្លួនមានលក្ខណៈតូចចង្អៀតជាង "បណ្ដាឯកសារ"និង"កម្រងឯកសារមួយ"។ នៅក្នុងកថាខណ្ឌចុងក្រោយនៃសំណើសុំ ក្រោមចំណងជើង"អាស្រ័យហេតុនេះ" ម្ចាស់បណ្ដឹងឧទ្ធរណ៍បានស្នើសុំសហចៅក្រមស៊ើបអង្កេតឱ្យដាក់ទៅក្នុងសំណុំរឿង នូវ "ឯកសារចំនួន ៦០០ ដែលត្រូវបានប្រើប្រាស់ជាឯកសារយោងនៅក្នុងរបាយការណ៍វិភាគ របស់លោក [Craig C.] Etcheson ដែលនៅមិនទាន់ត្រូវបានបញ្ចូលទៅក្នុងសំណុំរឿង នៅឡើយ" [២០]។

១៦. អង្គបុរេជំនុំជម្រះពិចារណាឃើញថា ផ្ដើមចេញពីសំណើសុំ និងពីបណ្ដឹងឧទ្ធរណ៍ផងដែរ[២១] វាបង្ហាញច្បាស់ណាស់ថា ការលើកឡើងនៅក្នុងសំណើសុំរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ចំពោះ "បណ្ដាឯកសារ" "កម្រងឯកសារ" "ឯកសារទាំងនេះ" "ឯកសារ" និង "ឯកសារចំនួន ៦០០ គឺសំដៅលើឯកសារតែមួយ ដែលជាឯកសារ DC-Cam ដូចដែលបានយោងនៅក្នុងកថាខណ្ឌទី ២៨ ខាងក្រោម។

[១៨] សំណើ កថាខណ្ឌ ១។

[១៩] សំណើ កថាខណ្ឌ ២។

[២០] សំណើ កថាខណ្ឌ ៧។

[២១] *ឧទាហរណ៍* បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៤៣។

00548019



១៧. សំណើសុំក៏បានទាមទារផងដែរថា "ឯកសារទាំងនេះមួយចំនួន [ឯកសារ DC-Cam] ត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងហើយ ប៉ុន្តែមួយចំនួនទៀតស្ថិតនៅក្នុងឃ្លាំងផ្ទុកឯកសាររួម នៅឡើយ[២២]។ ដូច្នេះ វាមិនស្ថិតនៅក្នុងសំណុំរឿងស៊ើបអង្កេតពិតប្រាកដរបស់លោក ខៀវ សំផន ឡើយ។ ការជ្រើសរើសនេះមិនមានមូលហេតុពន្យល់បានត្រឹមត្រូវឡើយ ហើយអាចប៉ះពាល់ដល់ផលប្រយោជន៍របស់លោក ខៀវ សំផន ហើយនិងប៉ះពាល់ដល់ការស្វែងរកការពិត"[២៣]។

## ដីការបស់សហចៅក្រមស៊ើបអង្កេត

១៨. សហចៅក្រមស៊ើបអង្កេតបានបដិសេធលើសំណើសុំ ពីព្រោះមេធាវីការពារ"មិនបានធ្វើការពន្យល់ទេថា ហេតុដូចម្តេចបានជាខ្លួនអាចធ្វើសេចក្តីសន្និដ្ឋានមួយដែលថា ឯកសារអស់ទាំងនោះ [គឺឯកសារ DC-Cam] "លើកឡើងអំពីសកម្មភាពជាក់ស្តែងរបស់លោក ខៀវ សំផន និងជាពិសេសមេធាវីការពារមិនបានបញ្ជាក់អំពីការចុះទៅពិនិត្យដោយផ្ទាល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីផ្ទៀងផ្ទាត់លើចំនួនឯកសារដែលគ្រប់គ្រងដោយ ប្រភពឯកសារសាធារណៈមួយនេះ ឬបានផ្ទៀងផ្ទាត់លើអត្ថន័យរបស់ឯកសារអស់ទាំងនោះទេ"[២៤]។ "លើសពីនេះទៀត" ពាក់ព័ន្ធទៅនឹងការយោងលើ"កម្រងឯកសារ" របស់ម្ចាស់បណ្តឹងឧទ្ធរណ៍នៅក្នុងសំណើសុំ សហចៅក្រមស៊ើបអង្កេតបានលើកឡើងថា:

> សំណើសុំមិនបានផ្តល់នូវការចង្អុលបង្ហាញណាមួយទៅលើការជ្រើសតាំងឯកសារអស់ទាំងនោះទេ។ ជាមួយគ្នានេះដែរ ក្រៅអំពីការលើកឡើងនូវអត្ថប្រយោជន៍ទូទៅនៃឯកសារដែលចុះហត្ថលេខាដោយ លោក ខៀវ សំផន ឬត្រូវបានសរសេរ ដោយរូបលោកផ្ទាល់ សំណើសុំមិនបានពន្យល់ទេថា តើឯកសារពិសេស ទាំងឡាយដែលមេធាវីការពារក្តីបានលើកឡើងថា ខ្លួនបានកំណត់អត្តសញ្ញាណ នៅក្នុងឃ្លាំងផ្ទុកឯកសាររួមរួចជាស្រេច

---

[២២] ដើងទំព័រលេខ ៤ ក្នុងសំណើសរសេរថា "ឯកសារនៅក្នុងឧបសម្ព័ន្ធ-គ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឯកសារតុលាការ *D3/IV*។ របាយការណ៍អនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ និងឧបសម្ព័ន្ធ (សរុបមានចំនួន ៥១ ឯកសារ) ឯកសារតុលាការ *D161/1 និង D161/1.1*"។

[២៣] សំណើ កថាខណ្ឌ ៦។

[២៤] ដីកាសម្រេច កថាខណ្ឌ ៤។



E.C.C.C. * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ហើយនោះ បានចូលរួមចំណែកដល់ការស្វែងរកការពិតទៅលើអង្គហេតុ ដែលជាកម្មវត្ថុនៃការស៊ើបអង្កេតអ្វីខ្លះ[២៥]។

១៩. "ហេតុនេះ" សហចៅក្រមស៊ើបអង្កេតបានពិចារណាឃើញថា "មេធាវីការពារមិនបានបំពេញកាតព្វកិច្ចរបស់ពួកគាត់ដូចដែលបានលើកឡើងពីខាងដើមឡើយ ទាក់ទងដល់ *សេចក្តីបញ្ជាក់ដំបូង (prima facie)* ដោយមានការបញ្ជាក់ឱ្យបានគ្រប់គ្រាន់អំពីភាពសមហេតុសមផល នៃសំណើសុំរបស់ខ្លួន ឬអំពីបញ្ជីនៃសំណុំឯកសារដែលជាកម្មវត្ថុនៃសំណើសុំ"[២៦]។

២០. សហចៅក្រមស៊ើបអង្កេតបញ្ចប់ដីការបស់ខ្លួន តាមរយៈការឆ្លើយតបទៅនឹងសេចក្តីថ្លែងការណ៍នៅក្នុងសំណើសុំថា "ការជ្រើសរើសសំណុំឯកសារសម្រាប់ដាក់បញ្ចូលក្នុងសំណុំរឿងមិនមានហេតុផលសមស្រប" ហើយថា "ឯកសារដែលលោក [បណ្ឌិត Etcheson] បានប្រើប្រាស់ជាឯកសារយោងហើយ ដែលច្រើនតែមាននៅក្នុងឧបសម្ព័ន្ធ នៃរបាយការណ៍របស់លោក ត្រូវតែដាក់បញ្ចូលទៅក្នុងសំណុំឯកសារ ដោយគ្មានការលើកលែងឡើយ"[២៧]។ សហចៅក្រមស៊ើបអង្កេតបានលើកឡើងជាការឆ្លើយតបថា:

> ដើម្បីកំណត់ថាភស្តុតាងណាមួយមានសារៈសំខាន់ដល់ការបង្ហាញការពិត ទោះបីជាភស្តុតាងនោះជាភស្តុតាងដាក់បន្ទុកក្តី ឬជាភស្តុតាងដោះបន្ទុកក្តី សហចៅក្រមស៊ើបអង្កេតត្រូវពិនិត្យមើលអំពីភាពសមហេតុសមផលនៃភស្តុតាងនោះ ដោយធៀបទៅនឹងអង្គហេតុដែលបានលើកឡើងក្នុងពាក្យបណ្តឹង ហើយនឹងពិនិត្យមើលផងដែរថា តើភស្តុតាងនោះពុំមានលក្ខណៈច្រំដែល បើធៀបទៅនឹងភស្តុតាងនានា ដែលបានដាក់បញ្ចូលទៅក្នុងសំណុំរឿងរួចហើយនោះ។
>
> ដូចដែលមេធាវីការពារធ្លាប់បានទទួលស្គាល់រួចមកហើយ សំណុំរឿងស៊ើបអង្កេត ត្រូវបានដាក់បញ្ចូលនូវឯកសារភស្តុតាងជាង ១០០ ឯកសារ ដែលពាក់ព័ន្ធជាមួយ នឹងរឿងពាណិជ្ជកម្ម ហើយដែលមានឯកសារមួយចំនួនពាក់ព័ន្ធជាមួយនឹងរូបលោក ខៀវ សំផន។ សហចៅក្រមស៊ើបអង្កេតត្រូវបង្ខំចិត្តកំណត់អំពីអត្តសញ្ញាណនៃឯកសារដែលផ្ញើទៅកាន់លោក ខៀវ សំផន ឬឯកសារដែល

---

[២៥] ដីកាសម្រេច កថាខណ្ឌ ៥។

[២៦] ដីកាសម្រេច កថាខណ្ឌ ៦ (ជើងទំព័រត្រូវបានលុប)។

[២៧] សំណើ កថាខណ្ឌ ៥-៦។



PRETRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

សរសេរដោយរូបលោកផ្ទាល់ ដែលឯកសារអស់ទាំងនោះមាននៅក្នុងឃ្លាំងផ្ទុកឯកសាររួម នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ឬនៅទីកន្លែងដទៃទៀត។ ឯកសារអស់ទាំងនោះត្រូវបានធ្វើការវិភាគជាពិសេសដើម្បី កំណត់អំពីប្រភេទនៃសកម្មភាពទាំងឡាយរបស់លោក ខៀវ សំផន ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ហើយឯកសារទាំងឡាយណា ដែលត្រូវបានចាត់ទុកថា មានសារៈ-ប្រយោជន៍ ដល់កិច្ចស្វែងរកការពិត ត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងផងដែរ។ ឯកសារដែលនៅសេសសល់ដទៃទៀត រាប់បញ្ចូលទាំងឯកសារ ដែលត្រូវបានចាត់ទុកថាមាន លក្ខណៈច្រំដែល ឬពុំមានហេតុផលសមស្របគ្រប់គ្រាន់ ឯកសារអស់ទាំងនេះត្រូវបានដាក់បញ្ចូលទៅក្នុងឃ្លាំងផ្ទុកឯកសាររួមតែមួយ[២៨]។

## ការសម្រេចសេចក្ដីនៃបណ្ដឹងឧទ្ធរណ៍

២១. អង្គបុរេជំនុំជម្រះរំលឹកថា សំណើសុំក្រោមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង:

> ត្រូវកំណត់ឱ្យច្បាស់នូវការស្នើសុំបំពេញកិច្ចស៊ើបសួរ *និង* រៀបរាប់មូលហេតុ ដែលភាគីស្នើសុំ យល់ឃើញថា មានភាពចាំបាច់សម្រាប់ដឹកនាំការស៊ើបអង្កេត។ករណីនេះ អនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតវាយតម្លៃថា តើសំណើសុំពាក់ព័ន្ធ ក្នុងការបង្ហាញការពិត និងផ្ដល់សំអាងហេតុនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន[២៩]។

២២. អានុភាពនៃលក្ខខណ្ឌត្រួតគ្នាទាំងពីររបស់វិធាន ៥៥(១០) នៃវិធានផ្ទៃក្នុងនេះ គឺថា វានឹងក្លាយជាការអនុវត្តយ៉ាងត្រឹមត្រូវនូវឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការបដិសេធសំណើសុំដែលបំពេញលក្ខខណ្ឌតែមួយប៉ុណ្ណោះក្នុងចំណោមលក្ខខណ្ឌទាំងនោះ។ អង្គបុរេជំនុំជម្រះយល់ឃើញថា សំណើសុំនេះបំពេញលក្ខខណ្ឌទីពីរនៃវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង (ការទាក់ទងដល់ *សេចក្ដីបញ្ជាក់ដំបូង (prima facie)*) ប៉ុន្តែ មិនបំពេញលក្ខខណ្ឌទីមួយ (សេចក្ដីពិស្ដារ និងភាពច្បាស់លាស់នៃសំណើសុំ)នោះទេ។ ហេតុនេះ អង្គបុរេជំនុំជម្រះនឹងពិនិត្យមើលលក្ខខណ្ឌទាំងពីររបស់វិធាន៥៥(១០)នៃវិធានផ្ទៃក្នុង នៅក្នុងសាលដីកានេះដែលជាផ្នែកមួយនៃការពិចារណា

[២៨] ដីកាសម្រេច កថាខណ្ឌ ៧-៨ (ជើងទំព័រត្រូវបានលុប)។

[២៩] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុក ឯកសាររួម ចុះថ្ងៃ ទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ ៥៤ (គូសបញ្ជាក់បន្ថែម)។

00548022



របស់ខ្លួនពាក់ព័ន្ធនឹងបញ្ហា ថាតើមានកំហុសអង្គច្បាប់ដែរឬទេ។ អង្គបុរេជំនុំជម្រះនឹងចាប់ផ្តើមលើមូលដ្ឋានទីពីរនៃបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងការទាក់ទងដល់ *សេចក្តីបញ្ជាក់ដំបូង(prima facie)* នៃសំណើសុំ។

**មូលដ្ឋានទីពីរនៃបណ្តឹងឧទ្ធរណ៍ - ការខកខានក្នុងការវាយតម្លៃអំពីភាពពាក់ព័ន្ធនៃសំណើសុំក្នុងលក្ខខណ្ឌ នៃការនាំទៅបង្ហាញនូវការពិតនៃ *សេចក្តីបញ្ជាក់ដំបូង (prima facie)* របស់វា។**

២៣. ម្ចាស់បណ្តឹងឧទ្ធរណ៍លើកឡើងថា ដីកា“មិនបានឆ្លើយតបទៅនឹងបញ្ញត្តិនៃច្បាប់ ដែលសម្រាប់អនុវត្តនោះទេ”[៣០] ពាក់ព័ន្ធជាមួយនឹងបទដ្ឋានដែលត្រូវអនុវត្តដោយសហចៅក្រមស៊ើបអង្កេត ដើម្បីសម្រេច ទៅលើសំណើសុំបំពេញកិច្ចស៊ើបសួរស្របតាមវិធាន៥៥(១០)នៃវិធានផ្ទៃក្នុង។ ម្ចាស់បណ្តឹង ឧទ្ធរណ៍លើកឡើងថា បទដ្ឋានដែលដីកាបានបង្កើតឡើង “ដាក់លក្ខខណ្ឌតឹងរឹង”[៣១]។ អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានពណ៌នាយ៉ាងត្រឹមត្រូវអំពីបទដ្ឋានច្បាប់សមស្រប[៣២]។ ទោះបីជាយ៉ាងណាក៏ដោយ អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានប្រព្រឹត្តកំហុសអង្គច្បាប់ តាមរយៈការធ្វើសេចក្តីសន្និដ្ឋានមិនត្រឹមត្រូវ បន្ទាប់ពីបានអនុវត្តនូវបទដ្ឋានច្បាប់ត្រឹមត្រូវរួច។

២៤. នៅក្នុងដីកា សហចៅក្រមស៊ើបអង្កេតលើកឡើងថា ម្ចាស់បណ្តឹងឧទ្ធរណ៍ “មិនបានធ្វើការពន្យល់ថា តើហេតុដូចម្តេចបានជាខ្លួនអាចធ្វើសេចក្តីសន្និដ្ឋានមួយដែលថា “ឯកសារអស់ទាំងនោះ [ឯកសារ DC-Cam] លើកឡើងអំពីសកម្មភាពជាក់ស្តែងរបស់លោក ខៀវ សំផន”។ អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមានភាពត្រឹមត្រូវក្នុងការយល់ឃើញថា មូលហេតុតែមួយគត់ដែលផ្តល់ឱ្យនៅក្នុងសំណើសុំពាក់ព័ន្ធនឹងបញ្ហាថាតើឯកសារDC-Cam“ត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង”នោះ គឺថាបណ្ឌិត Etcheson បានយោងលើឯកសារទាំងអស់នោះ “យ៉ាងជាក់

---

[៣០] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦១។

[៣១] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦១។

[៣២] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុក ឯកសាររួម ចុះថ្ងៃ ទី១៨ ខែវិច្ឆិកា ឆ្នាំ២00៩ ឯកសារ D164/4/13 កថាខណ្ឌ ៤១-៤៦។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * PRÉLIMINAIRE

ច្បាស់”នៅក្នុងរបាយការណ៍វិភាគជាលាយលក្ខណ៍អក្សររបស់គាត់(“របាយការណ៍វិភាគ”)[៣៣]។ អង្គបុរេជំនុំជម្រះយល់ឃើញថា មូលហេតុរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ថាតើ“ហេតុដូចម្តេចបានជាខ្លួនអាចធ្វើសេចក្តី-សន្និដ្ឋានមួយដែលថា ‘ឯកសារអស់ទាំងនោះ [ឯកសារ DC-Cam] លើកឡើងអំពីសកម្មភាពជាក់ស្តែងរបស់លោក ខៀវ សំផន’”នោះ មានភាពមិនច្បាស់លាស់ដោយចៀសមិនរួចនៅក្នុងសំណើសុំ និងអាចឱ្យសហចៅក្រមស៊ើបអង្កេតយកទៅធ្វើការពិចារណាបាន។

២៥. នៅក្នុងសំណើសុំ ព័ត៌មានជាក់ស្តែងតែមួយគត់ដែលបានផ្តល់ឱ្យស្តីពីឯកសារ DC-Cam គឺជាការពណ៌នាទូទៅស្តីពីឯកសារទាំងនោះធ្វើឡើងដោយបណ្ឌិត Etcheson នៅក្នុងរបាយការណ៍វិភាគរបស់គាត់។ នៅក្នុងកថាខណ្ឌទី១ នៃផ្នែករង “សេដ្ឋកិច្ច” ក្រោមផ្នែក “គណៈអចិន្ត្រៃយ៍” បណ្ឌិត Etcheson បានសរសេរដូចខាងក្រោម:

> [31] គណៈអចិន្ត្រៃយ៍បានអនុវត្តការត្រួតត្រាមជ្ឈិមលើសេដ្ឋកិច្ចកម្ពុជាទាំងមូល តាមរយៈ មន្ទីរ 870 ភាគច្រើន ប៉ុន្តែមិនមែនទាំងអស់នោះទេ។ ផែនការ តម្លៃ ផលិតកម្ម ការនាំចេញ នាំចូល និងការប្រើប្រាស់ ត្រូវបានគ្រប់គ្រងដោយមជ្ឈិម បក្សទាំងអស់។ ឧទាហរណ៍ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា មានរបាយការណ៍ និងអនុស្សរណៈស្តីពីប្រធានបទទាំងនេះ ដែលត្រូវបានផ្ញើទៅមកពី ខៀវ សំផន ក្នុងមន្ទីរ 870។ ឯកសារទាំងនេះពាក់ព័ន្ធគ្រប់លក្ខណៈទាំងអស់នៃសេដ្ឋកិច្ច ប៉ុន្តែ ឯកសារជាច្រើនផ្តោតលើការទាញយកផលិតកម្មបន្ថែមពី បណ្តាភូមិភាគទាំងឡាយ ដើម្បីរក្សាទុកបែងចែកឡើងវិញ និងសម្រាប់ការនាំចេញ។

២៦. នៅក្នុងកថាខណ្ឌទី ១ នៃផ្នែករង “ទំនាក់ទំនង” ក្រោមផ្នែក “ក្រសួងនានា” បណ្ឌិត Etcheson បានសរសេរដូចខាងក្រោម:

> [146] គំរូឯកសារទំនាក់ទំនងជុំវិញក្រសួងទាំងឡាយរបស់កម្ពុជាប្រជាធិបតេយ្យ បង្ហាញឱ្យឃើញថា មានរចនាសម្ព័ន្ធតិចជាងគំរូឯកសារទំនាក់ទំនង ពាក់ព័ន្ធនឹងផ្នែករដ្ឋបាលនយោបាយ សន្តិសុខផ្ទៃក្នុង និងរចនាសម្ព័ន្ធយោធា។ ថ្នាក់លើ (ជាពិសេសគណៈអចិន្ត្រៃយ៍

[៣៣] ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ D២-១៥ (“របាយការណ៍វិភាគ”)។

និងមន្ទីរ 870) ក្រសួងនានា និងថ្នាក់ ក្រោមមានបណ្ដាញជាច្រើនក្នុងការទំនាក់ទំនងពីមួយទៅមួយ។ ខ្សែបណ្ដាញទាំងអស់នេះហាក់ដូចជាកំពុងប្រើប្រាស់ស្របគ្នា។ ជាឧទាហរណ៍ ក្រសួង នីមួយៗរាយការណ៍ និងទទួលការណែនាំពីថ្នាក់មជ្ឈិម តាមរយៈយន្តការជាច្រើន ដូចជាកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ កិច្ចប្រជុំក្រុមប្រឹក្សារដ្ឋមន្ត្រី និងការប្រជុំទល់មុខពិសេស ឬប្រជុំជាក្រុមតូចៗជាមួយមេដឹកនាំជាន់ខ្ពស់ ដូចជា ប៉ុល ពត ឬ នួន ជា និងប្រជុំហ្វឹកហ្វឺនទ្រង់ទ្រាយធំ និងចុះពិនិត្យតាមអង្គភាពនីមួយៗរបស់អង្គការដោយគណៈប្រតិភូមេដឹកនាំជាន់ខ្ពស់។ គេបានបន្ថែមការទំនាក់ទំនងគ្នាដោយផ្ទាល់នេះ តាមរយៈការផ្លាស់ប្ដូរគ្នារវាងថ្នាក់លើ និងថ្នាក់ក្រសួងនានា ជាទម្រង់លិខិតតេឡេក្រាម អនុស្សរណៈ និងរបាយការណ៍ (ប្រចាំសប្ដាហ៍ ឬប្រចាំខែ) ព្រមទាំងសេចក្ដីណែនាំគោលនយោបាយ និងការឃោសនាបក្ស ដូចជាព្រឹត្តិប័ត្រ *ទង់បដិវត្ត*។ ឧទាហរណ៍ មានរបាយការណ៍យ៉ាងច្រើនជូនចំពោះ ខៀវ សំផន នៅមន្ទីរ 870។ របាយការណ៍ទាំងនេះបានពិភាក្សាលើប្រធានបទចាប់ពីស្ថិតិប្រចាំថ្ងៃ អំពីផលិតកម្មស្រូវ របាយការណ៍ប្រចាំខែ ប្រចាំ សប្ដាហ៍អំពីការដឹកជញ្ជូន ផលិតផលពីភូមិភាគទៅមជ្ឈិម ចរន្តនាំចេញនាំចូល តាមរយៈកំពង់ផែកំពង់សោម និងកិច្ចប្រជុំនៅក្រសួងពាណិជ្ជកម្ម ក្រសួងការបរទេស និងស្ថានទូតបរទេស [ជើងទំព័រលេខ ៣៤១ ដើមដែលបានបង្កើតឡើងខាងក្រោម]។

២៧. នៅក្នុងជើងទំព័រលេខ ៣៤១ នៅចុងកថាខណ្ឌនេះ បណ្ឌិត Etcheson បានសរសេរ ដូចខាងក្រោម:

> បណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា មានឯកសារគំរូអំពីទំនាក់ទំនងប្រភេទនេះ មានចំនួន ច្រើនជាង ៦០០ ឯកសារគំរូ ទាក់ទងនឹង ខៀវ សំផន នៅមន្ទីរ ៨៧០ ដែលទទួលបានពីបណ្ណសារជាតិនៃកម្ពុជា រៀបរាប់ចាប់ពីរបាយការណ៍ប្រចាំថ្ងៃ អំពីផលិតកម្មស្រូវ រហូតដល់របាយការណ៍ប្រចាំឆ្នាំពាក់ព័ន្ធនឹង សកម្មភាពនានានៃភូមិភាគទាំងឡាយ ក្រសួងនានា និងនៅថ្នាក់ផ្សេងៗទៀត។

២៨. អង្គបុរេជំនុំជម្រះយោងឯកសារ "របាយការណ៍ និងអនុស្សរណៈរាប់រយច្បាប់" ព្រមទាំង "ឧទាហរណ៍ជាង ៦០០ នៅក្នុងលិខិតឆ្លើយឆ្លងប្រភេទនេះ" ដែលបានពណ៌នាដោយ បណ្ឌិត Etcheson នៅក្នុងរបាយការណ៍វិភាគរបស់ខ្លួន ថាជា "ឯកសារ DC-Cam"។

២៩. អង្គបុរេជំនុំជម្រះយល់ឃើញថា ការពណ៌នាសង្ខេបរបស់បណ្ឌិត Etcheson អំពីឯកសារ DC-Cam មិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីសន្និដ្ឋានថា ឯកសារទាំងអស់នោះពិតជានាំទៅបង្ហាញនូវការពិតនោះទេ។ អង្គបុរេជំនុំជម្រះយល់ឃើញថា នៅពេលដែលម្ចាស់បណ្ដឹងឧទ្ធរណ៍បានលើកឡើងនៅក្នុងបណ្ដឹងឧទ្ធរណ៍នៅពេលក្រោយមកទៀត វាត្រូវតែច្បាស់លាស់ណាស់ ចំពោះសហចៅក្រមស៊ើបអង្កេត ដែលថា ឯកសារ DC-Cam មាន ការទាក់ទងដល់ *សេចក្ដីបញ្ជាក់ដំបូង (prima facie)* ក្នុងការនាំទៅបង្ហាញនូវការពិត ពីព្រោះ "ឯកសារទាំងនោះសុទ្ធសឹងជាឯកសារផ្លូវការដែលប្រើប្រាស់នៅក្នុងរបប [ខ្មែរក្រហម]នោះ ហើយវាបានបំភ្លឺអំពីតួនាទីរបស់លោក ខៀវ សំផន នៅក្នុងសម័យ កម្ពុជាប្រជាធិបតេយ្យ ជាឯកសារដែលពាក់ព័ន្ធជាមួយលោក ខៀវ សំផន ហើយជាឯកសារដែលបំភ្លឺអំពីវត្តមានរបស់លោក ខៀវ សំផន នៅក្នុងប្រទេសកម្ពុជានាសម័យកម្ពុជាប្រជាធិបតេយ្យ និងអំពីមុខងាររបស់លោកក្នុងសម័យនោះផងដែរ"[៣៤]។

៣០. អង្គបុរេជំនុំជម្រះទទួលស្គាល់ថា វាគ្មានលក្ខណៈច្បាស់លាស់នោះទេ ថាតើបណ្ឌិត Etcheson ដែលត្រូវបានថ្លែងនៅក្នុងសំណើសុំ ថាជាប្រភពព័ត៌មានជាក់ស្ដែងតែមួយ គត់ពាក់ព័ន្ធនឹងឯកសារ DC-Camនោះ បានផ្អែកសេចក្ដីសន្និដ្ឋានណាមួយក្នុងចំណោម សេចក្ដីសន្និដ្ឋានទាំងឡាយរបស់ខ្លួនដែលមាននៅក្នុងរបាយការណ៍វិភាគ សូម្បីតែមួយផ្អែកក៏ដោយ លើរបាយការណ៍ណាមួយក្នុងចំណោម "របាយការណ៍ និងអនុស្សរណៈ រាប់រយច្បាប់" ជាក់លាក់ ឬក៏ "ឧទាហរណ៍ជាង ៦០០ នៅក្នុងលិខិតឆ្លើយឆ្លងប្រភេទនេះ" ដែលគាត់បានយកធ្វើជាសំអាង។

៣១. អង្គបុរេជំនុំជម្រះក៏បានកត់សម្គាល់ឃើញផងដែរថា នៅក្នុងដីកាសហចៅក្រមស៊ើបអង្កេតខ្លួនឯងហាក់ដូចជាឯកភាពថា "ឯកសារភស្ដុតាង ដែលពាក់ព័ន្ធជាមួយនឹងរឿងពាណិជ្ជកម្ម...ដែលមានការពាក់ព័ន្ធជាមួយនឹងរូបលោក ខៀវ សំផន" ត្រូវបាន "ធ្វើការ វិភាគ... ដើម្បីកំណត់អំពីប្រភេទនៃសកម្មភាពទាំងឡាយរបស់លោក ខៀវ សំផន ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ហើយឯកសារ

[៣៤] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៦៦។



E.C.C.C * C.E.T.C PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ទាំងឡាយណាដែលត្រូវបានចាត់ទុកថា មានសារៈប្រយោជន៍ដល់កិច្ចស្វែងរកការពិត... បានដាក់បញ្ចូលក្នុងសំណុំរឿងផងដែរ"[៣៥]។ នេះជាមូលហេតុដែលសហចៅក្រមស៊ើបអង្កេត "ត្រូវបង្ខំចិត្តកំណត់អំពីអត្តសញ្ញាណនៃ ឯកសារដែលផ្ញើទៅកាន់លោក ខៀវ សំផន ឬឯកសារដែលសរសេរដោយរូបលោកផ្ទាល់ ដែលឯកសារអស់ទាំងនោះមាននៅក្នុងឃ្លាំងផ្ទុកឯកសាររួម នៅមជ្ឈមណ្ឌលឯកសារ កម្ពុជា ឬនៅទីកន្លែងដទៃទៀត"[៣៦]។

៣២. នៅក្នុងបណ្តឹងឧទ្ធរណ៍ តាមរយៈការធ្វើសេចក្តីសន្និដ្ឋាន ម្ចាស់បណ្តឹងឧទ្ធរណ៍សួរសំណួរ អំពីមូលហេតុដែលនាំឱ្យសហចៅក្រមស៊ើបអង្កេត "ត្រូវបង្ខំចិត្តកំណត់អំពីអត្តសញ្ញាណ នៃឯកសារភស្តុតាង ដែលពាក់ព័ន្ធជាមួយនឹងរឿងពាណិជ្ជកម្ម... ដែលមានការពាក់ព័ន្ធជាមួយនឹងរូបលោក ខៀវ សំផន" ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនពិចារណាឃើញថា ឯកសារទាំងនោះមានការទាក់ទងដល់ *សេចក្តីបញ្ជាក់ដំបូង (prima facie)* ក្នុងការនាំទៅបង្ហាញនូវការពិតទេនោះ[៣៧]។ អង្គបុរេជំនុំជម្រះពិចារណាឃើញថា ចម្លើយតបរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ទៅនឹងសំណួររបស់ខ្លួនគឺត្រឹមត្រូវ: "សហចៅក្រមស៊ើបអង្កេត *ទាក់ទងដល់សេចក្តីបញ្ជាក់ដំបូង (prima facie)* យល់ឃើញថាឯកសារទាំងនោះ មានប្រយោជន៍ដល់ការស្វែងរកការពិត"[៣៨]។

៣៣. អង្គបុរេជំនុំជម្រះយល់ឃើញថា សំណើសុំមានមូលហេតុ *ទាក់ទងដល់សេចក្តីបញ្ជាក់ដំបូង (prima facie)* សម្រាប់សហចៅក្រមស៊ើបអង្កេតជឿជាក់ថា ឯកសារ DC-Cam ដែលបណ្ឌិត Etchesonបានយកធ្វើជាសំអាងនៅក្នុងកថាខណ្ឌទី៣១ និងជើងទំព័រលេខ៣៤១ នៃរបាយការណ៍វិភាគរបស់គាត់មានប្រយោជន៍ដល់ការស្វែងរកការពិត។ សហចៅក្រមស៊ើបអង្កេតមានកំហុសអង្គច្បាប់រួមគ្នានឹងកំហុសនៃអង្គហេតុ តាមរយៈការធ្វើសេចក្តីសន្និដ្ឋានផ្សេងពីនេះ[៣៩]។ ហេតុនេះ

---

[៣៥] ដីកាសម្រេច កថាខណ្ឌ ៨។

[៣៦] ដីកាសម្រេច កថាខណ្ឌ ៨។

[៣៧] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦៩។

[៣៨] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦៩។ *សូមមើលផងដែរ* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៤។

[៣៩] ដីកាសម្រេច កថាខណ្ឌ ៤, ៦។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

អង្គបុរេជំនុំជម្រះមិនចាំបាច់ធ្វើការពិចារណាលើសេចក្តីសន្និដ្ឋានដែលនៅសេសសល់របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ក្រោមមូលដ្ឋានទីពីរនិងទីបីនៃបណ្តឹងឧទ្ធរណ៍ឡើយ[៤០]។

៣៤. កំហុសនេះមិននាំឱ្យមានការបដិសេធដីកាទុកជាឥតបានការនោះទេ ពីព្រោះ ដូចនឹងកិច្ចពិភាក្សាដែលនឹងធ្វើឡើងខាងក្រោម អង្គបុរេជំនុំជម្រះយល់ឃើញថា សំណើសុំមិនកំណត់អត្តសញ្ញាណកិច្ចស៊ើបសួរដែលបានស្នើសុំឱ្យបានច្បាស់លាស់នោះទេ, ហេតុដូច្នេះ ត្រូវបានចៅក្រមស៊ើបអង្កេតធ្វើការបដិសេធយ៉ាងសមហេតុផល។

៣៥. ពេលនេះ អង្គបុរេជំនុំជម្រះពិនិត្យមើលមូលដ្ឋានទីមួយនៃបណ្តឹងឧទ្ធរណ៍ ពាក់ព័ន្ធទៅនឹង បញ្ហាថា តើសំណើសុំបានកំណត់ច្បាស់លាស់ដែរឬទេលើអត្តសញ្ញាណកិច្ចស៊ើបសួរដែលបានស្នើសុំ។

**មូលដ្ឋានទីមួយនៃបណ្តឹងឧទ្ធរណ៍ - ការអនុវត្តខុសនូវលក្ខខណ្ឌកំណត់សម្រាប់ការបញ្ជាក់ឱ្យបានគ្រប់គ្រាន់អំពីភាពសមហេតុសមផលនៃសំណើសុំ ស្របតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង**

៣៦. ម្ចាស់បណ្តឹងឧទ្ធរណ៍លើកឡើងថា "លក្ខខណ្ឌកំណត់អំពីការបញ្ជាក់ឱ្យបានគ្រប់គ្រាន់ អំពីភាពសមហេតុសមផល"ដែលបានរៀបរាប់នៅក្នុងដីកា"មានលក្ខណៈហួសពីកាតព្វកិច្ចដែលបានកំណត់ដោយអង្គបុរេជំនុំជម្រះ ហើយលក្ខខណ្ឌដូចនេះមិនមានសុពលភាពទេ"[៤១]។ ម្ចាស់បណ្តឹងឧទ្ធរណ៍ក៏បានលើកឡើងថា ខ្លួន"បានបញ្ជាក់យ៉ាងច្បាស់លាស់អំពីប្រភេទនៃកិច្ចស៊ើបសួរដែលខ្លួនបានទាមទារនៅក្នុងសំណើសុំរបស់ខ្លួន"[៤២] និងថា ខ្លួន"បានលើកឡើងយ៉ាងច្បាស់លាស់អំពីឯកសារទាំងនោះ និងអំពីប្រភពរបស់វាផងដែរ"[៤៣]។

៣៧. អង្គបុរេជំនុំជម្រះសម្រេចថា សំណើសុំមិន"មានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់ក្នុងការ បង្ហាញយ៉ាងច្បាស់ទៅសហចៅក្រមស៊ើបអង្កេត អំពីចំណុចអ្វី ដែលសហចៅក្រមស៊ើបអង្កេតគួរស្រាវ

---

[៤០] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥៤-៥៩, ៦២-៦៥, ៧៦-៨៣។

[៤១] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥១។

[៤២] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៣។ *សូមមើលផងដែរ* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៧។

[៤៣] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៥។



E.C.C.C * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ជ្រាវ”[៤៤] ដោយយោងលើសំអាងហេតុដូចតទៅ។ ជាដំបូង សេចក្តីសន្និដ្ឋានរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ដែលថា “ឯកសារដែលបានលើកឡើង [គឺឯកសារ DC-Cam] ដែលបានយោងដោយ [បណ្ឌិត Etcheson]”[៤៥] មិនត្រឹមត្រូវនោះទេ។ ជាការពិត បណ្ឌិត Etcheson បានយោងលើឯកសារDC-Camក្នុងលក្ខណៈទូទៅ។ គាត់មិនបានធ្វើការដកស្រង់ឯកសារណាមួយក្នុងចំណោមឯកសារទាំងនេះនៅក្នុងចំណុចទាំងពីរនៃរបាយ ការណ៍វិភាគ (កថាខណ្ឌទី ៣១ និងជើងទំព័រលេខ ៣៩១) ដែលគាត់បានធ្វើការសំអាងជាទូទៅនោះទេ។ ទីពីរ ផ្ទុយទៅនឹងអ្វី ដែលម្ចាស់បណ្តឹងឧទ្ធរណ៍បានអះអាង[៤៦] វាមិនច្បាស់លាស់សោះសម្រាប់អង្គបុរេជំនុំជម្រះ ថាតើសហព្រះរាជអាជ្ញាមានឯកសារ DC-Cam ណាខ្លះ ប្រសិនបើមាននោះ។ ទីបី វាមិនច្បាស់លាស់ទេថា តើបណ្ឌិត Etcheson បានដកស្រង់ ឯកសារ DC-Cam ណាមួយនៅក្នុងឧបសម្ព័ន្ធ ក, ខ ឬ គ យកទៅដាក់នៅក្នុងរបាយការណ៍វិភាគរបស់ខ្លួននោះ។ ទីបួន ចំនួននៃឯកសារ DC-Cam មិនមានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់ចំពោះអង្គបុរេជំនុំជម្រះនោះទេ ពីព្រោះអាចមានឯកសារ ចំនួន “រាប់រយ” ឬ “ជាង៦០០”។ ទីប្រាំ វាមិនច្បាស់លាស់ទេដែលថា តើឯកសារ DC-Cam ទាំងពីរក្រុម (“របាយការណ៍ និងអនុស្សរណៈរាប់រយច្បាប់” និង“ឧទាហរណ៍ជាង ៦០០ នៅក្នុងលិខិតឆ្លើយឆ្លងប្រភេទនេះ”) មានឯកសារដូចគ្នាឬយ៉ាងណា។

៣៨. មូលហេតុចុងក្រោយ ដែលអង្គបុរេជំនុំជម្រះពិចារណាឃើញថា សំណើសុំមិន“កំណត់អត្តសញ្ញាណឲ្យបានច្បាស់លាស់អំពីកិច្ចស៊ើបសួរដែលបានស្នើសុំ”[៤៧] គឺថា សំណើសុំមិនច្បាស់លាស់ទេ ថាតើឯកសារDC-Cam មាននៅក្នុងឃ្លាំងផ្ទុកឯកសាររួម ឬមាននៅក្នុងសំណុំរឿងរួចហើយ។ នៅក្នុងសំណើសុំ ម្ចាស់បណ្តឹងឧទ្ធរណ៍អះអាងថា “ឯកសារមួយ ចំនួន [គឺឯកសារ DC-Cam] ត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿងរួចហើយ ខណៈពេលដែលឯកសារផ្សេងទៀតនៅ

---

[៤៤] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃ ទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ ៤៥។

[៤៥] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៧៦។ *សូមមើលផងដែរ* សំណើ កថាខណ្ឌ ៣។

[៤៦] បណ្តឹងឧទ្ធរណ៍ ជើងទំព័រ ៥៥។

[៤៧] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុក ឯកសាររួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ ៤៤។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C.

រក្សាទុកក្នុងឃ្លាំងផ្ទុកឯកសាររួមនៅឡើយ"[៤៨]។ នៅក្នុងជើងទំព័រលេខ៤ នៃសំណើសុំម្ចាស់បណ្តឹងឧទ្ធរណ៍អះអាងផ្តល់សេចក្តីដកស្រង់ថា "ឯកសារមួយចំនួន [ដែល] ត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿងរួចហើយ"។ ក៏ប៉ុន្តែ ដោយសារតែសំណើសុំមិនបានផ្តល់សេចក្តីដកស្រង់ជាក់លាក់ណាមួយអំពីតុល្យភាពនៃចំនួនឯកសារDC-Cam ដែលគ្មាននៅក្នុងសំណុំរឿង សំណើសុំមិនអាចនាំឱ្យសហចៅក្រមស៊ើបអង្កេតធ្វើការសន្និដ្ឋានអំពីចំនួន ឬទីកន្លែងរបស់ឯកសារDC-Cam ដែលមិនមាននៅក្នុងសំណុំរឿងបានឡើយ។ មានតែនៅក្នុងបណ្តឹងឧទ្ធរណ៍ប៉ុណ្ណោះ ហើយមិនមែននៅក្នុងសំណើសុំទេ ដែលម្ចាស់បណ្តឹងឧទ្ធរណ៍លើកឡើងថា ឯកសារ"ជាច្រើន" ដែលខ្លួនបានរកឃើញនៅមជ្ឈមណ្ឌលឯកសារកម្ពុជា "យោងទៅលើដីការបស់សហចៅក្រមស៊ើបអង្កេត... ពុំត្រូវបានសង្កេតឃើញមាននៅក្នុងសំណុំរឿង ឬនៅក្នុងឃ្លាំងផ្ទុកឯកសាររួមទេ"[៤៩]។

៣៩. ដោយខ្វះនូវការពណ៌នាឱ្យបានច្បាស់លាស់អំពីខ្លឹមសារ និងទីតាំង ការស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតធ្វើការស្រាវជ្រាវរក ធ្វើការកំណត់អត្តសញ្ញាណ និងធ្វើការវិភាគលើឯកសារទាំងឡាយដែលពិបាករក មិនស្របជាមួយនឹង"កាតព្វកិច្ចចាត់ចែងនៅក្នុងរបៀបមួយ ដែលនឹងមិនពន្យារពេលដល់ដំណើរការនីតិវិធី" របស់ម្ចាស់បណ្តឹងឧទ្ធរណ៍នោះទេ[៥០]។ ពាក់ព័ន្ធនឹងបញ្ហានេះដែរ អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមិនមានកំហុសដោយបានពិចារណា "ជាពិសេស"ថា ម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានបញ្ជាក់នៅក្នុងសំណើសុំ "អំពីការចុះទៅពិនិត្យដោយផ្ទាល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីផ្ទៀងផ្ទាត់លើចំនួនឯកសារដែលគ្រប់គ្រងដោយប្រភពឯកសារសាធារណៈមួយនេះឬបានផ្ទៀងផ្ទាត់លើអត្ថន័យរបស់ឯកសារអស់ទាំងនោះទេ"[៥១]។ ជាលទ្ធផល អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនត្រឹមត្រូវហើយ។

---

[៤៨] សំណើ កថាខណ្ឌ ៦។

[៤៩] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៧២។

[៥០] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ ៤៥។

[៥១] ដីកាសម្រេច កថាខណ្ឌ ៤។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

00548030



៤០. អង្គបុរេជំនុំជម្រះបដិសេធបណ្តឹងឧទ្ធរណ៍ទុកជាឥតបានការ ដោយហេតុថា សំណើសុំមិនបានកំណត់កិច្ចស៊ើបសួរឱ្យបានជាក់លាក់គ្រប់គ្រាន់។ ហេតុនេះ អង្គបុរេជំនុំជម្រះមិនចាំបាច់ធ្វើការពិចារណាអំពីសេចក្តីសន្និដ្ឋានដែលនៅសេសសល់របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ក្រោមមូលដ្ឋានទីមួយនៃបណ្តឹងឧទ្ធរណ៍ទេ[៥២]។

៤១. យោងលើសំអាងហេតុដូចបានលើកឡើងខាងលើ អង្គបុរេជំនុំជម្រះបានសម្រេចតាមការប្រកាសនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១០។

យោងតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះបិទផ្លូវតវ៉ា។

ភ្នំពេញ ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១០

ចៅក្រមអង្គបុរេជំនុំជម្រះ ប្រធាន

Rowan DOWNING ន័យ ថុល Catherine MARCHI-UHEL ហួត វុទ្ធី ប្រាក់ គឹមសាន

[៥២] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៨-៥៣។